## កាឡាទី ៦:១-១៨

**ការរំលឹក**: យោងតាមកាឡាទី ៥:១៦-២៦ យើងរៀនបានថា «សាច់ឈាមតែងតែប៉ងប្រាថ្នាទាស់នឹងព្រះវិញ្ញាណ ឯព្រះវិញ្ញាណ ទ្រង់ក៏ទាស់នឹងសាច់ឈាមដែរ សេចក្ដីទាំង២នោះប្រឆាំងនឹងគ្នា» (៥:១៧)។ អស់អ្នកដែលប្រព្រឹត្តតាមសាច់ឈាមមិនបានគ្រងនគរព្រះទុកជាមរដកឡើយ (៥:២១)។ ដូច្នេះយើងត្រូវរស់ដោយនូវព្រះវិញ្ញាណ (៥:២៥)។

សូមអានកាឡាទី ៦:១-១៨ ទាំងមូល។
សូមអានខ.១ ឡើងវិញហើយឆ្លើយសំនួរខាងក្រោម។

*បើបានទាន់ឃើញមនុស្សណាធ្វើខុសអ្វីនោះយើងត្រូវធ្វើដូចម្ដេច?*

**ការពន្យល់**: នៅក្នុង ៥:២២-២៥ លោកប៉ុលបង្រៀនថា បើសិនជាយើងរស់ដោយនូវព្រះវិញ្ញាណ នោះយើងមានផលផ្លែនៃព្រះវិញ្ញាណ លើសពីនេះទៅទៀត យើងបានឆ្កាងសាច់ឈាមហើយ ព្រមទាំងសេចក្ដីរំជួលនិងសេចក្ដីប៉ងប្រាថ្នាទាំងប៉ុន្មានផង។ ប៉ុន្តែការបង្រៀននេះមិនមានន័យថា យើងជាមនុស្សល្អឥតខ្ចោះទេ។ ៦:១ បង្ហាញថា គ្រីស្ទបរិស័ទនៅតែមានបាបនិងការល្បួងនៅក្នុងជីវិតមែន។

**សំនួរអនុវត្ត**: *តើ គ្រីស្ទបរិស័ទនៅក្នុងពួកជំនុំរបស់អ្នកធ្លាប់តម្រង់បងប្អូនណាដែលធ្វើខុសឬទេ? បើធ្លាប់ តើគេតម្រង់ដោយចិត្តសុភាពឬទេ?*

សូមអាន ខ.២ *តើ លោកប៉ុលជំរុញយើងអោយធ្វើអ្វី?*

**ការពន្យល់**: «ក្រិត្យវិន័យនៃព្រះគ្រីស្ទ» ប្រហែលជាសំដៅទៅ ៥:១៤។
សូមអាន ខ.៣-៥ *តើ យើងបញ្ឆោតខ្លួនឯងដោយរបៀបណា?*

**ការអនុវត្ត**: *ចូរពិនិត្យពិច័យមើលអំពើដែលអ្នកប្រព្រឹត្តនៅក្នុងគ្រួសារ ពួកជំនុំ និងសង្គម។ តើ អ្នកត្រូវផ្លាស់ប្ដូរអំពើណាមួយឬទេ?*

*តើ អ្នកធ្លាប់ប្រៀបធៀបខ្លួនឯងជាមួយនឹងអ្នកដទៃដែរទេ?*

**ការពន្យល់**: នៅក្នុង ៥:២៦-៦:៥ លោកប៉ុលបានព្រមានគ្រីស្ទបរិស័ទអំពីបាបដែលមកដោយអំនួត។ ដោយអំនួតយើងអួតបំប៉ោង រករឿង និងមានចិត្តឈ្នានីស។ អ្នកដើរដោយព្រះវិញ្ញាណមិនអាចដំរង់អ្នកមានបាបដោយអំនួតបានទេ ប៉ុន្តែត្រូវដំរង់គេដោយចិត្តស្លូតបូតវិញ។ អំនួតនាំយើងប្រៀបធៀបខ្លួនឯងជាមួយនឹងអ្នកដទៃ ហើយតាមធម្មតាយើងលើកតម្លៃខ្លួនឯងខ្ពស់។

សូមអាន ខ.៦។ *តើ អ្នកដែលទទួលការអប់រំខាងព្រះបន្ទូល ត្រូវធ្វើអ្វី?*
**សំនួរអនុវត្ត**: *តើ អ្នកធ្លាប់យករបស់ល្អទាំងប៉ុន្មានដែលខ្លួនមាន មកចែកដល់អ្នកដែលអប់រំខ្លួនឬទេ?*

សូមអាន ខ.៧-១០។ *តើអ្នកណាដែលព្រោះខាងសាច់ឈាមរបស់ខ្លួន និងច្រូតបានអ្វី?*

*តើអ្នកណាដែលព្រោះខាងឯព្រះវិញ្ញាណ នោះនឹងច្រូតបានអ្វី?*

*តើលោកប៉ុលបានបង្រៀនអ្វីដើម្បីយើងមិនណាយចិត្តនឹងធ្វើការល្អ?*

**ការពន្យល់ និងអនុវត្ត**: លោកប៉ុលបានលើកយកឧទាហរណ៍មួយពីកសិកម្មមកជំរាបថា យើងត្រូវមានមានចិត្តអត់ធ្មត់ ដូចជាកសិករទន្ទឹងរង់ចាំភោគផលផងដែរ (ប្រៀបធៀប យ៉ាកុប ៥:៧-៨)។ ប្រហែលជាលោកិយល្បួងគ្រីស្ទបរិស័ទតាមរយៈភ្នែក ធ្វើឲ្យឃើញថា លោកិយហាក់ដូចជាមានជីវិតស្រួលជាងឬសប្បាយជាង ប្រសិនបើពួកគេសាបព្រោះតាមនិស្ស័យលោកិយរបស់ពួកគេ ប៉ុន្តែគ្រីស្ទបរិស័ទមិនត្រូវចាប់អារម្មណ៍នឹងអ្វីៗ ដែលភ្នែកមើលឃើញនោះឡើយ តែយើងត្រូវចាប់អារម្មណ៍នឹងអ្វីៗ ដែលភ្នែកមើលមិនឃើញនោះវិញ (២កូរិនថូស ៤:១៨) ដូច្នេះយើងទន្ទឹងរង់ចាំថ្ងៃដែលព្រះគ្រីស្ទយាងមកវិញ។ ដូច្នេះយើងត្រូវប្រព្រឹត្តអំពើល្អចំពោះមនុស្សទាំងអស់ (ខ.១០)។ *តើការយាងមកវិញរបស់ព្រះគ្រីស្ទលើកទឹកចិត្តអ្នកអោយប្រព្រឹត្តអំពើល្អចំពោះអ្នកដទៃ ឬឲ្យចាប់អារម្មណ៍នឹងអ្វីៗ ដែលភ្នែកមើលឃើញ?*

សូមអាន ខ.១១-១៦។ *គ្រូក្លែងក្លាយដែលបង្ខំឱ្យពួកកាឡាទីទទួលកាត់ស្បែក បានធ្វើដូច្នេះដើម្បីអ្វី? (ខ.១២-១៣)*។

*តើ លោកប៉ុលអួតបានតែពីអ្វី?*

*តើ លោកប៉ុលបានអង្វរសូមព្រះជាម្ចាស់ប្រទានអ្វី?*
**ការពន្យល់**: តាមធម្មតានៅសម័យនោះ មនុស្សដែលផ្ញើសំបុត្រ បាននិទានដល់អ្នកផ្សេងទៀតដែលត្រូវតែរក្សាទុកអ្វីដែលគាត់និយាយ។ នៅខ.១១ ប៉ុលជំរាបថា គាត់បានសរសេរសំបុត្រនេះដោយដៃរបស់ខ្លួនផ្ទាល់។ យោងតាម ៥:១១ យើងរៀនបានថា ដំណឹងល្អអំពីព្រះគ្រីស្ទជាប់ឆ្កាងធ្វើអោយគេរវាតចិត្ត (សូមមើលមេរៀនពី ៥:១-១៥)។ ហេតុនោះបានជាគេបៀតបៀនលោកប៉ុល។ ជនជាតិយូដាអៀនខ្មាស មិនហ៊ានទទួលដំណឹងល្អអំពីឈើឆ្កាង ប៉ុន្តែលោកប៉ុល (ដែលជាជនជាតិយូដាដែរ) បានសម្រេចចិត្តថា គាត់អួតបានតែពីឈើឆ្កាងនៃព្រះគ្រីស្ទប៉ុណ្ណោះ។
**សំនួរពិចារណា**: *តើអ្នកធ្លាប់អៀនខ្មាស មិនហ៊ានទទួលឬប្រកាសដំណឹងល្អអំពីឈើឆ្កាងដែរទេ? តើ គំរូរបស់លោកប៉ុលបានលើកទឹកចិត្តអ្នកយ៉ាងម៉េចដែរ?*

សូមអាន ខ.១៧-១៨។ *តើ លោកប៉ុលមានអ្វីនៅក្នុងរូបកាយរបស់គាត់? តើ ត្រង់កន្លែងនេះគាត់ស្តីអំពីអ្វី?*

**ការពន្យល់និងអនុវត្ត**: លោកប៉ុលបានទទួលសេចក្ដីទុក្ខលំបាកដោយសារដំណឹងល្អរបស់ព្រះគ្រីស្ទ។ សព្វថ្ងៃនេះផងដែរមានគ្រូប្រកាសដំណឹងល្អដែលទទួលសេចក្ដីទុក្ខលំបាក ហើយយើងត្រូវអធិស្ឋានអោយពួកគាត់ ហើយមិនត្រូវធ្វើអោយពួកគាត់ពិបាកចិត្តឲ្យសោះ។
**រំលឹកឡើងវិញ** តើយើងបានរៀនអ្វីចេញពីកាឡាទី ៦:១-១៨?

**ការអនុវត្ត**: *តាមអ្វីដែលអ្នកបានរៀនតាមរយៈបទគម្ពីរនេះ តើអ្នកត្រូវយកវាមកអនុវត្តន៍យ៉ាងដូចម្ដេចនាពេលសព្វថ្ងៃនេះ?*